ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកិច្ចការនារី

លេខ ១៧៩ កកន/ប្រក

# ប្រកាស
# ស្តីពី
# ការបង្កើតក្រុមការងារអន្តរក្រសួង ដើម្បីរៀបចំសេចក្តីព្រាងច្បាប់ ស្តីពី ការគ្រប់គ្រងការពពោះជំនួស

## រដ្ឋមន្ត្រីក្រសួងកិច្ចការនារី

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០២ ចុះថ្ងៃទី១៧ ខែ មករា ឆ្នាំ២០០៥ ដែលបានប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកិច្ចការនារី
- បានឃើញអនុក្រឹត្យលេខ ១៣ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០០៥ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងកិច្ចការនារី
- យោងតាមលិខិតលេខ ១២៦៥ ស.ជ.ណ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ស្តីពីការអនុញ្ញាតជាគោលការណ៍ឱ្យក្រសួងកិច្ចការនារីរៀបចំសេចក្តីព្រាងច្បាប់ថ្មី និងអនុញ្ញាតក្នុងការបង្កើតក្រុមការងារអន្តរក្រសួងដែលមានសមាសភាពចូលរួមពីស្ថាប័នពាក់ព័ន្ធមួយចំនួន ។
- យោងតាមលិខិតចាត់តាំងរបស់រដ្ឋមន្ត្រី ក្រសួងសុខាភិបាល ក្រសួងយុត្តិធម៌ ក្រសួងសង្គមកិច្ចនិងយុវនីតិសម្បទា ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ។
- យោងតាមការចាំបាច់ ។

## សម្រេច

**ប្រការ ១.-**

បង្កើតក្រុមការងារអន្តរក្រសួង ដើម្បីរៀបចំសេចក្តីព្រាងច្បាប់ ស្តីពីការគ្រប់គ្រងការពពោះជំនួសមានគោលបំណង លើកកម្ពស់ សិទ្ធិ សុខុមាលភាព សុវត្ថិភាពស្ត្រី និងកុមារ និងទប់ស្កាត់ការធ្វើអាជីវកម្ម ឬ

ផ្លូវទ្រុងមាន់ ភូមិដំណាក់ធំ៣ សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ (ភ្នំពេញ)
ទូរស័ព្ទ : ០២៣ ៨៨២ ០៤៧ / ៨៨២ ០៤៨
៨៨២ ០៣៩ / ៨៨២ ០៤៩

ការធ្វើសកម្មភាពយកផលកម្រៃពីសេវាពពោះជំនួសស្របតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និង មានគោលបំណងពង្រឹងការអនុវត្តឱ្យបានសម្រេចតាមអនុសញ្ញាស្តីពី ការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងស្ត្រីភេទ ឬឧបករណ៍ ឬ កិច្ចព្រមព្រៀងអន្តរជាតិផ្សេងៗដែលព្រះរាជាណាចក្រកម្ពុជាបានផ្តល់សច្ចាប័ន ឬ ចុះហត្ថលេខា ។

ក្រុមការងារអន្តរក្រសួង មានសមាសភាពតំណាងមកពីក្រសួង ស្ថាប័នពាក់ព័ន្ធរួមមាន ៖

| | | | |
|---|---|---|---|
| ១. លោកជំទាវវេជ្ជ. | **អ៊ឹង កន្ថាផាវី** | រដ្ឋមន្ត្រីក្រសួងកិច្ចការនារី | ប្រធាន |
| ២. លោកជំទាវ | **ចាន់ សុទ្ធាវី** | រដ្ឋលេខាធិការក្រសួងយុត្តិធម | អនុប្រធាន |
| ៣. លោកជំទាវ | **តាន់ ឌួចនេច** | រដ្ឋលេខាធិការក្រសួងសុខាភិបាល | អនុប្រធាន |
| ៤. លោកជំទាវ | **សាន្ត អរុណា** | រដ្ឋលេខាធិការក្រសួងកិច្ចការនារី | អនុប្រធានអចិន្ត្រៃយ៍ |
| ៥. លោកជំទាវ | **ច័ន្ទ ហារ៉ានវឌ្ឍី** | អនុរដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា | សមាជិក |
| ៦. លោកជំទាវ | **រ៉ែន សិរីលក្ខិណា** | អគ្គលេខាធិការរងនៃ គ.ជ.ប.ជ | សមាជិក |
| ៧. ឯកឧត្តម | **សូរ ឌីម៉ា** | អនុប្រធានក្រុមប្រឹក្សានីតិកម្មក្រសួងមហាផ្ទៃ | សមាជិក |
| ៨. លោកជំទាវ | **ប៊ុន ពុទ្ធី** | អនុរដ្ឋលេខាធិការ ក្រសួងកិច្ចការនារី | សមាជិក |
| ៩. លោកស្រី | **សាខឿន សាវ៉ាតឌី** | អគ្គនាយករង អគ្គនាយកដ្ឋានអភិវឌ្ឍន៍សង្គម ក្រសួងកិច្ចការនារី | សមាជិក |
| ១០. លោកស្រី | **ជា ហ៊ឹង** | អគ្គនាយករងអគ្គនាយកដ្ឋានរដ្ឋបាល និងកិច្ចការទូទៅ | សមាជិក |
| ១១. លោកវេជ្ជបណ្ឌិត | **ឈា ឆវណ្ណា** | ប្រធានវិទ្យាស្ថានសុខភាពសាធារណៈ ក្រសួងសុខាភិបាល | សមាជិក |
| ១២. លោកស្រី | **សូរ ដានី** | អគ្គលេខាធិការរង នៃក្រសួងយុត្តិធម | សមាជិក |
| ១៣. លោក | **ថូ សំណាង** | ប្រធាននាយកដ្ឋានច្បាប់និងកុងស៊ុល ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ១៤. លោកឧត្តមសេនីយ៍ត្រី | **ភែប សារឿន** | ប្រធាននាយកដ្ឋានកិច្ចការយុត្តិធម៌ ក្រសួងមហាផ្ទៃ | សមាជិក |
| ១៥. លោក | **ឈួរ សុបញ្ញា** | ប្រធាននាយកដ្ឋានសុខុមាលភាពសង្គម ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | សមាជិក |
| ១៦. លោក | **អ៊ឹង វណ្ណថា** | អនុប្រធាននាយកដ្ឋានច្បាប់និងកុងស៊ុលក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |

១៧. តំណាង ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សមាជិក

**ប្រការ ២.-**

ក្រុមការងារអន្តរក្រសួង មានតួនាទី និងភារកិច្ចដូចខាងក្រោម៖

- ដឹកនាំ បែងចែកការទទួលខុសត្រូវរបស់ក្រុមការងារអន្តរក្រសួង
- ដឹកនាំ រៀបចំ សម្របសម្រួល ចាត់ចែងការប្រជុំនានាដែលទាក់ទងសេចក្តីព្រាងច្បាប់
- ចូលរួមយ៉ាងសកម្មក្នុងកិច្ចប្រជុំទាំងឡាយ ដើម្បីពិភាក្សា ពិនិត្យមើលឡើងវិញ និងផ្តល់យោបល់ទៅលើសេចក្តីព្រាងច្បាប់នេះ និង ឯកសារផ្សេងៗទៀតនៃកិច្ចសហប្រតិបត្តិរួមគ្នាតាមការចាំបាច់
- ផ្តល់ការជួយគាំទ្រគ្នាទៅវិញទៅមក នៅក្នុងដំណើរការពិភាក្សាពិគ្រោះយោបល់ជាមួយនឹងស្ថាប័នពាក់ព័ន្ធ អង្គការមិនមែនរដ្ឋាភិបាល និង អាជ្ញាធរផ្សេងៗដើម្បីសម្របសម្រួលការរៀបចំសេចក្តីព្រាងច្បាប់
- ផ្តល់ការគាំទ្រទៅវិញទៅមកក្នុងលំហូរព័ត៌មានទាំងឡាយដែលទាក់ទងនឹងកិច្ចសហប្រតិបត្តិការរួមគ្នា
- សហការក្នុងការរៀបចំ តាក់តែង ការអនុម័ត សេចក្តីព្រាងច្បាប់នេះឱ្យមានភាពរលូនប្រកបដោយប្រសិទ្ធភាព
- ទំនាក់ទំនងស្ថាប័នពាក់ព័ន្ធក្នុងការស្វែងរកជំនួយថវិកា និងបច្ចេកទេសនានា ដែលរួមចំណែកក្នុងការអភិវឌ្ឍន៍សេចក្តីព្រាងច្បាប់
- ផ្តល់មន្ត្រីបង្គោលថ្នាក់បច្ចេកទេស ដើម្បីអនុវត្តសកម្មភាពទាំងឡាយ ព្រមទាំងសម្របសម្រួលលំហូរនៃការប្រាស្រ័យទាក់ទងគ្នា នៅក្នុងការងារបច្ចេកទេស
- ក្រុមការងារអន្តរក្រសួង ប្រជុំសាមញ្ញ និង វិសាមញ្ញ តាមការចាំបាច់។

**ប្រការ ៣.-**

ក្រុមការងារអន្តរក្រសួង បង្កើតក្រុមការងារបច្ចេកទេស ដែលមានសមាសភាពដូចខាងក្រោម៖

| | | | |
|---|---|---|---|
| ១. លោកជំទាវ | **ម៉ុន ពុទ្ធី** | អនុរដ្ឋលេខាធិការ ក្រសួងកិច្ចការនារី | ប្រធាន |
| ២. លោកវេជ្ជបណ្ឌិត | **ឈា ឆវណ្ណា** | ប្រធានវិទ្យាស្ថានសុខភាពសាធារណៈ ក្រសួងសុខាភិបាល | អនុប្រធាន |
| ៣. លោកស្រី | **សួរ ដានី** | អគ្គលេខាធិការរង នៃក្រសួងយុត្តិធម៌ | អនុប្រធាន |
| ៤. លោកស្រី | **សាឡឿន សាវ៉ាតឌី** | អគ្គនាយករង អគ្គនាយកដ្ឋានអភិវឌ្ឍន៍សង្គម ក្រសួងកិច្ចការនារី | អនុប្រធានអចិន្ត្រៃយ៍ |
| ៥. លោកឧត្តមសេនីយ៍ត្រី | **កែប សារឿន** | ប្រធាននាយកដ្ឋានកិច្ចការយុត្តិធម៌ | |

ty SA

| | | | |
|---|---|---|---|
| | | ក្រសួងមហាផ្ទៃ | សមាជិក |
| ៦. លោកស្រី | **ឡេង មោនីភាព** | ប្រធាននាយកដ្ឋានស្ត្រីនិងសុខភាព | សមាជិក |
| ៧. លោកស្រី | **ហ៊ូ និរមិត្តា** | ប្រធាននាយកដ្ឋានសមភាពយេនឌ័រ | សមាជិក |
| ៨. លោក | **ឈួរ សុបញ្ញា** | ប្រធាននាយកដ្ឋានសុខុមាលភាពសង្គម ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | សមាជិក |
| ៩. លោក | **អ៊ឹង វណ្ណថា** | អនុប្រធាននាយកដ្ឋានច្បាប់និងកុងស៊ុលក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ១០. លោក | **ខិន ចន** | អនុប្រធាននាយកដ្ឋានការពារផ្លូវច្បាប់ ក្រសួងកិច្ចការនារី | សមាជិក |
| ១១. លោក | **តែ សុខា** | ប្រធានការិយាល័យផ្នែកច្បាប់ | សមាជិក |
| ១២. លោក | **ផុន ពុធបូរី** | ប្រធានការិ.ផ្សាយតាមទូរទស្សន៍ | សមាជិក |
| ១៣.លោកស្រី | **ស៊ុន ម៉ូនិច** | អនុប្រធានការិ.ប្រឆាំងការជួញដូរស្ត្រី | សមាជិក |
| ១៤. លោកស្រី | **គីម ស្រីមុំ** | ជំនួយការ លោកជំទាវ សាន្ត អរុណ | សមាជិក |
| ១៥. កញ្ញា | **ខែម ឆារី** | លេខាធិការ លោកជំទាវ ប៊ុន ពុទ្ធី | សមាជិក |

**ប្រការ ៤.-**

ក្រុមការងារបច្ចេកទេស មានតួនាទីនិងភារកិច្ចដូចខាងក្រោមនេះ៖

- ក្រុមការងារបច្ចេកទេស ជាសេនាធិការឱ្យក្រុមការងារអន្តរក្រសួង
- ធ្វើការងារប្រចាំថ្ងៃជាមួយអ្នកជំនាញអន្តរជាតិ ក្នុងការរៀបចំតាក់តែងសេចក្តីព្រាងច្បាប់ ឱ្យមានភាពរលូន និងមានប្រសិទ្ធភាព
- ចូលរួមក្នុងកិច្ចប្រជុំ តាមរយៈវត្តមាន ផ្តល់មតិយោបល់ទៅលើសេចក្តីព្រាងច្បាប់ កំណត់ហេតុប្រជុំ និងឯកសារពាក់ព័ន្ធផ្សេងៗទៀត
- ធ្វើកំណត់ហេតុប្រជុំ របាយការណ៍ ជូនក្រុមការងារអន្តរក្រសួងពិនិត្យ និងផ្តល់យោបល់ត្រឡប់ ដោយធ្វើការបូកសរុបជូនថ្នាក់ដឹកនាំជាទៀងទាត់
- រៀបចំរបៀបវារៈនៃកិច្ចប្រជុំ រៀបចំឯកសារពាក់ព័ន្ធ រក្សាទុក និងចែកចាយដល់ក្រុមការងារទាំងអស់
- រៀបចំ និងកែសម្រួលសេចក្តីព្រាងច្បាប់ តាមការឯកភាពយល់ព្រមរួមគ្នានៅក្នុងក្រុមការងារ មុននឹងបញ្ជូនទៅក្រុមការងារអន្តរក្រសួង

- ក្រុមការងារបច្ចេកទេសត្រូវប្រជុំក្រុមក្នុងមួយខែ ២ដង ដើម្បីពិនិត្យលទ្ធផលការងារ និងរាយការជូនក្រុមការងារអន្តរក្រសួង។

**ប្រការ ៥.–**

លោកជំទាវ ឯកឧត្តម លោកស្រី លោក ដែលមានឈ្មោះនៅក្នុងប្រការ១ ប្រការ៣ ត្រូវអនុវត្តឱ្យបានល្អ និងមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី២៦ ខែ[illegible]ឆ្នាំ២០១៧

**រដ្ឋមន្ត្រី**

**អ៊ឹង កន្ធាផាវី**

**ចម្លងជូនៈ**

- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ក្រសួងយុត្តិធម៌
- ក្រសួងសុខាភិបាល
- ក្រសួងសង្គមកិច្ចអតីតយុទ្ធជន និង យុវនីតិសម្បទា
- អគ្គលេខាធិការដ្ឋាននៃគ.ជ.ប.ជ
- ដូចប្រការ៥
- ឯកសារ-កាលប្បវត្តិ